**ព្រឹទ្ធសភា**

**អគ្គលេខាធិការដ្ឋាន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែឧសភា និងទិសដៅការងារខែមិថុនា ឆ្នាំ២០១៤

នៅក្នុងខែឧសភានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម លើការដ្ឋានជាច្រើន ដោយផ្សារភ្ជាប់បទដ្ឋានការងាររដ្ឋបាល បច្ចេកទេស នីតិវិធី និងហិរញ្ញវត្ថុ ជាពិសេសការធ្វើរបាយការណ៍ចន្លោះសម័យប្រជុំ របាយការណ៍តាមវិស័យ រៀបចំប្រជុំគណៈកម្មការជំនាញ គណៈកម្មាធិការអចិន្ត្រៃយ៍ សម័យប្រជុំពេញអង្គ លើកទី៩ ការបណ្តុះបណ្តាលធនធានមនុស្ស ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងសកម្មភាពការងារសង្គម និងខិតខំពង្រឹងពង្រីកភាពសុខដុមផ្ទៃក្នុង បង្កើតសេវាថ្មីៗ កសាងគោលនយោបាយនានា បង្កើនកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ និងបំពេញការងារសំខាន់ៗមួយចំនួនទៀតដូចខាងក្រោម៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

-បានចាត់ចែងរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន០៣លើក ប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០២លើក និងប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ជួបពិភាក្សាជាមួយស្ថានទូតជប៉ុន គណៈប្រតិភូព្រឹទ្ធសភាថៃ គណៈប្រតិភូឡាវ ចូលរួមសន្និសីទថ្នាក់ពិភពលោក ស្តីពីសភាអេឡិចត្រូនិច (World e-parliament Conference )នៅទីក្រុងសេអ៊ូល នៃសាធារណរដ្ឋកូរ៉េ និងចូលរួមប្រជុំពិភាក្សាការងារផ្សេងៗ ព្រមទាំងបានពិនិត្យសម្រេចលើឯកសារផ្សេងៗចំនួន៩៣៨ច្បាប់ ។

### ១.សេវាទ្រទ្រង់មុខងារនីតិកម្ម៖

-បានរៀបចំប្រជុំផ្ទៃក្នុងគណៈកម្មការជំនាញ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៥ ។

### ២.សេវាទ្រទ្រង់មុខងារតំណាង៖

-ទទួលពាក្យបណ្តឹងចំនួន ០២ករណី និងបានបញ្ជូនលិខិតទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដោះស្រាយបានចំនួន០២ករណី និងទទួលបានលិខិតឆ្លើយតបពីការដោះពាក្យបណ្តឹងចំនួន០១បណ្តឹង ។

-រៀបចំបែបបទ និងអមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ចុះទៅតាមបណ្ដាខេត្ត រាជធានីទូទាំងប្រទេសចំនួន១១៤លើក ដើម្បីសំណេះសំណាល ជួបពិភាក្សាការងារ សាកសួរសុខទុក្ខ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន ៤២លើក ។

**៣.ការងារអន្តរជាតិ៖**

-ស៊ារលិខិតចែករំលែកទុក្ខទៅជូនថ្នាក់ដឹកនាំឡាវក្នុងឧបទ្ទវហេតុធ្លាក់យន្តហោះ ។

-ជួបពិភាក្សាការងារជាមួយឯកអគ្គរដ្ឋទូតរុស្ស៊ី គណៈប្រតិភូខុទ្ទកាល័យរដ្ឋសភាឡាវ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាថៃ លោកស្រី សាស៊ីថន ស្រីស៊ូចារីត ទីប្រឹក្សាទទួលបន្ទុកនីតិវិធី នៃនីតិបញ្ញត្តិ និងអ្នកការទូតជប៉ុន ។

-ជួបសម្ភាសន៍ជាមួយតំណាងទីភ្នាក់ងារអភិវឌ្ឍន៍ស្វីស ស្ដីពីជំនួយដល់វិទ្យាស្ថានសភាកម្ពុជា, វិទ្យុVOA, RFA និងVOD អំពីភាពរសើប នៃច្បាប់ចំនួន០៣ ។

-រៀបចំបែបបទជូនគណៈប្រតិភូព្រឹទ្ធសភា ទៅចូលរួមកិច្ចប្រជុំសន្និសីទអេឡិចត្រូនិចពិភពលោក នៅប្រទេសកូរ៉េ ចូលរួមកិច្ចប្រជុំរវាងអាយប៉ា និងថ្នាក់ដឹកនាំអាស៊ាន នាជំនួបកំពូលអាស៊ាន លើកទី២៤ នៅប្រទេសមីយ៉ាន់ម៉ា ចូលរួមកិច្ចប្រជុំ ALFOCOM លើកទី១១ នៅប្រទេសឡាវ និងចូលរួមកិច្ចប្រជុំត្រីភាគីបូក នៅសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន ។

-រៀបចំបែបបទជូនមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៧រូប ទៅចូលរៀនវគ្គបណ្ដុះបណ្ដាលនៅសាធារណរដ្ឋកូរ៉េ និងបន្តការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកការអភិវឌ្ឍន៍ និងអភិបាលកិច្ច នៅប្រទេសអាល្លឺម៉ង់ ។

-ទំនាក់ទំនងជាមួយដៃគូអន្តរជាតិ ឥណ្ឌា ថៃ ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

**៤.ទំនាក់ទំនងសាធារណៈ៖**

-ទំនាក់ទំនងជាមួយស្ថានីយ៍ទូរទស្សន៍ជាតិ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានា របស់ព្រឹទ្ធសភា និងសាកលវិទ្យាល័យ AEU ដើម្បីសុំអាហារូបករណ៍ ។

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត សាធារណៈជន ចូលអានសៀវភៅ ចំនួន៣២៣នាក់ ។

**៥.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-បើកវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន០២វគ្គ ស្តីពីការសរសេរព័ត៌មាន និងការថតរូប វគ្គ Microsoft Office Excel 2010 វគ្គសារព័ត៌មាន និងវគ្គវិធីសាស្ត្រក្នុងការរៀបចំគ្រប់គ្រង និងត្រួតពិនិត្យគម្រោង ។

-មន្ត្រីចំនួន០៩រូប ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីព័ត៌មានវិទ្យា នៅប្រទេសវៀតណាម ០២រូប ចូលរួមវគ្គច្បាប់សមុទ្រ និងសន្តិសុខដែនសមុទ្រ និង០១រូបទៀត ចូលរួមវគ្គភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងការទូត នៅប្រទេសម៉ាឡេស៊ី ។

**៦.ការអភិវឌ្ឍស្ថាប័ន៖**

-រដ្ឋាភិបាលចិនយល់ព្រមសាងសង់អគារ១ខ្នង ជូនព្រឹទ្ធសភា ។

-រដ្ឋសភាវៀតណាម បានបញ្ជូនក្រុមអ្នកឯកទេស០២នាក់ ចុះមកសិក្សាអំពីការបំពាក់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន នៅក្នុងព្រឹទ្ធសភាកម្ពុជា ។

-ការរៀបចំជួសជុលឡើងវិញអតីតអគារសម្ព័ន្ធភាពជាតិឃុំ-សង្កាត់ ធ្វើជាមជ្ឈមណ្ឌលបច្ចេកវិទ្យាព័ត៌មាន ។

-ការបន្តសំអាតម៉ាបនៅអគារចិនថ្មី៣ខ្នង ។

**៧. ការងារផ្ទៃក្នុង សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែង៖**

-ធ្វើរបាយការណ៍ចន្លោះសម័យប្រជុំ របាយការណ៍តាមវិស័យ លើកទី៤ និងលើកទី៥ នីតិកាលទី៣ ព្រឹទ្ធសភា ។

-កាត់ឯកសណ្ឋានជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

-ការបន្តកិច្ចសន្យាដល់អ្នកជាប់កិច្ចសន្យាតាមអង្គភាពនានា ។

-បញ្ចប់ការរៀបចំយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល (២០១៥-២០១៧) និងឯកសារពាក់ព័ន្ធនឹងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

-រៀបចំនីតិវិធីប្រលងផ្ទេរក្របខណ្ឌមន្ត្រីរាជការ ។

-អង្គភាពសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា បានចាត់កងកម្លាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន០៦លើក ។

-ថតចម្លងឯកសារ ចំនួន១០០សំណើ ចងក្រងឯកសារជាសៀវភៅ ចំនួន២២ក្បាល ដោះស្រាយសំណើថវិកា ចំនួន២២៤សំណើ និងសម្ភារចំនួន៥៥សំណើ ព្រមទាំងផ្តល់សេវាដឹកជញ្ជូនចំនួន ៧៨លើក ។

-ទទួលសម្ភារខូច ម៉ាស៊ីនហ្វូតូកូពីUPS, Keyboard, CPU, Monitor, Printer, កៅអីវិលតូចធំ ចំនួន៣១គ្រឿង ប្រគល់ទូទឹកកក កុំព្យូទ័រលើតុ តុប្រជុំ កៅអីពូកពណ៌ក្រហម ចំនួន២៩គ្រឿង បំពាក់ទូរទស្សន៍ ចំនួន០១គ្រឿង និងបិទលេខកូដម៉ាស៊ីនបញ្ចាំងស្លាយ និងតុដែក ចំនួន ០៣គ្រឿង ។ បញ្ចូលហ្គាស ជួសជុល ម៉ាស៊ីនត្រជាក់ បន្ទប់ទឹក ទូរស័ព្ទ ប្តូរអំពូល ព្រី កុងតាក់ សោទ្វារ និងដៃទ្វារបន្ទប់ ចំនួន៩៩គ្រឿង ។

-ជួសជុលកុំព្យូទ័រ ត្រួតពិនិត្យ បញ្ចូលកម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីខ្មែរ Unicode, Office ចុះតាមដាន Internet និង Network សរុបចំនួន១៣ ។

## II.ទិសដៅការងារខែមិថុនា ឆ្នាំ២០១៤

**១.សេវាទ្រទ្រង់មុខងារនីតិកម្ម៖**

-ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំពេញអង្គព្រឹទ្ធសភា (លទ្ធភាពថ្ងៃទី១០ និង១២ មិថុនា ២០១៤) ។

**២.សេវាទ្រទ្រង់មុខងារត្រួតពិនិត្យ/ ព័ត៌មាន៖**

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត ។

**៣.សេវាទ្រទ្រង់មុខងារតំណាង៖**

-ការរៀបចំវេទិកាសាធារណៈរបស់ក្រុមសមាជិកព្រឹទ្ធសភា តាមភូមិភាគ រួមទាំងវេទិកាក្រុមសមាជិកាព្រឹទ្ធសភា ។

**៤.ការងារអន្តរជាតិ៖**

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអង្គទូតនានា ។

-គម្រោងជួបអគ្គរដ្ឋទូតអាល្លឺម៉ង់ និងឯកអគ្គរដ្ឋទូតកាណាដា ។

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា បំពេញបេសកកម្មក្រៅប្រទេស រួមទាំងអគ្គលេខាធិការដ្ឋាន៖

-ទស្សនកិច្ចសិក្សា នៅប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី ថៃ ខែកញ្ញា ២០១៤

-កិច្ចប្រជុំនៅ OTTAWA ខែមិថុនា/កក្កដា

-ទស្សនកិច្ចនៅប្រទេសចិន (គណៈកម្មការទី៥)

-កិច្ចប្រជុំនៅប្រទេសសេរីលង្កា ។

-កិច្ចសហប្រតិបត្តិការជាមួយ KOICA, JICA, CAMSERV, វៀតណាម ឥណ្ឌា ឥណ្ឌូនេស៊ី សឹង្ហបុរី

ម៉ាឡេស៊ី កូរ៉េ ចិន ប្រ៊ុយណេ វិទ្យាស្ថានធនាគារពិភពលោក វិទ្យាស្ថានសភាកម្ពុជា និងដៃគូផ្សេងទៀត ។

-បន្តយុទ្ធនាការស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង/ក្រៅប្រទេស សំរាប់ព្រឹទ្ធសភាតាមរយៈវិទ្យាស្ថានសភាកម្ពុជា ។

**៥.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-ត្រៀមរៀបចំបែបបទជូនមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅចូលរៀនវគ្គសិក្សាភាសាអង់គ្លេស នៅប្រទេសថៃ និងវគ្គរដ្ឋបាលសាធារណៈ នៅប្រទេសម៉ាឡេស៊ី ។

-ជំរុញលើកកម្ពស់ចំណេះដឹង ជំនាញភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន និងយកចិត្តទុកដាក់ដល់ការពង្រឹងវិន័យ និងសណ្ដាប់ធ្នាប់សាធារណៈ ។

**៦.ការងារផ្ទៃក្នុង សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែង៖**

-ត្រៀមរៀបចំសម្រាប់ព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតានរោត្តម មុនិនាថ សីហនុ និងទិវាកុមារអន្តរជាតិ ។

-រៀបចំគម្រោងថវិកាឆ្នាំ២០១៩ របស់ព្រឹទ្ធសភា (ឆ្លងគណៈកម្មការទី២ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ។

-ពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិរបស់គ្រប់អង្គភាពអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆមាសទី១ ឆ្នាំ២០១៨ ។

-កសាងឯកសារស្តីពីក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពរយៈពេលវែង សម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា (២០១៨-២០២៨) និងឯកសារស្តីពីទស្សនវិស័យនៃដំណើរការឈានទៅមុខរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (២០១៨-២០២៨) ។

-យកចិត្តទុកដាក់ពង្រឹងពង្រីកប្រសិទ្ធភាពការងាររបស់បណ្ណាល័យ និង បណ្ណសារដ្ឋាន ។

-រៀបចំចងក្រងប្រវត្តិព្រឹទ្ធសភា និងប្រវត្តិអគារ ធ្វើបច្ចុប្បន្នភាព និងថែរក្សាឯកសារសហប្រតិបត្តិការជាមួយដៃគូ ។

-បង្កើនសមត្ថភាពស្រាវជ្រាវអំពីឯកសារ និងទិន្នន័យបច្ចុប្បន្នភាពរបស់ជាតិ ដើម្បីពង្រឹងសមត្ថភាពការងារ ។

-សិក្សាអំពីការដាក់ឲ្យអនុវត្តអង្គភាពថវិកា សម្រាប់០៤អង្គភាព ជាជំហានដំបូង ។

-បន្តពង្រឹងដំណើរការកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងជំរុញការចាប់ផ្តើមដំណើរការរបស់អង្គភាពសវនកម្មផ្ទៃក្នុង ។

## III.សេចក្តីសន្និដ្ឋាន

ក្នុងខែឧសភានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងមមាញឹក ក្នុងការធ្វើរបាយការណ៍ចន្លោះសម័យប្រជុំ របាយការណ៍តាមវិស័យ រៀបចំប្រជុំគណៈកម្មការជំនាញ គណៈកម្មាធិការអចិន្ត្រៃយ៍ សម័យប្រជុំពេញអង្គ លើកទី៥ ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៥ ព្រមទាំងបានធ្វើការងារអន្តរជាតិប្រកបដោយលទ្ធផល ( ជាមួយចិន វៀតណាម កូរ៉េ ស្វីស កាណាដា អាល្លឺម៉ង់) ទោះបីមានការឈប់ច្រើន (បុណ្យទិវាពលកម្មអន្តរជាតិ ព្រះរាជពិធីបុណ្យចំរើនព្រះជន្មព្រះមហាក្សត្រ បុណ្យវិសាខបូជា បុណ្យច្រត់ព្រះនង្គ័ល ព្រមទាំងការបោះឆ្នោតអសកលជ្រើសរើសសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ) ។ល។

ភ្នំពេញ,ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤

**អគ្គលេខាធិការ**

**អ៊ុំ សារិទ្ធ**